# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សហគមន៍កសិកម្ម តាសីសាមគ្គី**

# ឯកសារពិគ្រោះថ្លៃ
# ស្តីពីការជីកស្រះចំនួន ២ស្រះ

**លេខ៖ ១.១**

## មាតិកា


សេចក្តីអញ្ជើញចូលរួមពិគ្រោះថ្លៃ

ទម្រង់ទី១៖ បញ្ជីប៉ាន់តម្លៃ និងប្រតិទិនការងារ

ទម្រង់ទី២៖ លក្ខណៈបច្ចេកទេស និងគំនូសប្លង់

ទម្រង់ទី៣៖ ពាក្យសុំពិគ្រោះថ្លៃ

ទម្រង់ទី៤៖ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃ

ទម្រង់ទី៥៖ លិខិតបញ្ជាអនុវត្តការងារសាងសង់/ជួសជុល

ទម្រង់ទី៦៖ លក្ខខណ្ឌនៃកិច្ចសន្យា

ទម្រង់ទី៧៖ សេចក្តីប្រកាសអំពីក្រមសីលធម៌ និងការក្លែងបន្លំ និងអំពើពុករលួយ

ឧបសម្ព័ន្ធ១៖ ក្រមប្រតិបត្តិបរិស្ថាន(ESCOP) សម្រាប់ការជីកស្រះទឹកចំនួន១៨ សហគមន៍កសិកម្មតាសីសាមគ្គី

# សេចក្តីអញ្ជើញចូលរួមពិគ្រោះថ្លៃ

(ផ្សព្វផ្សាយឡើងវិញ)

## សហគមន៍កសិកម្មតាសីសាមគ្គី

## មានបំណងជីកស្រះចំនួន ២ស្រះ

(១) សហគមន៍កសិកម្ម របស់យើងខ្ញុំបានទទួលមូលនិធិ ពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលផ្តល់ហិរញ្ញប្បទាន ដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ (IDA) ហើយមានបំណងប្រើប្រាស់មូលនិធិនេះដើម្បីធ្វើការទូទាត់នៅក្រោម កិច្ចសន្យាសម្រាប់ការងារសាងសង់/ជីកស្រះ លេខកិច្ចសន្យា ១.១ ។ ទំហំការងារ និងការបរិយាយការងារសាងសង់/ ជីកស្រះ ត្រូវអនុវត្តទៅ តាមប្រតិទិនការងារដូចមានរាយក្នុងទម្រង់ទី១៖ បញ្ជីប៉ាន់តម្លៃ និង ប្រតិទិនការងារ។

(២) ការងារសាងសង់/ជីកស្រះ មានរយៈពេល **៦០ថ្ងៃ** ចាប់ពីថ្ងៃបានចុះហត្ថលេខាលើកិច្ចសន្យា។

(៣) អ្នកទទួលការទាំងឡាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានចំណាប់អារម្មណ៍ សូមអញ្ជើញមកទទួល ឯកសារពិគ្រោះថ្លៃ (ដោយឥតគិតថ្លៃ) នៅ**សហគមន៍កសិកម្មតាសីសាមគ្គី** ការិយាល័យសហគមន៍កសិកម្ម អាស័យដ្ឋាន នៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង លេខទូរសព្ទ លេខទូរសព្ទ ០៨៩ ៦៦១ ០៩៩។ អ្នកទទួលការអាចទាក់ទងទៅឈ្មោះ **ចៀង សុជាត** ជាជំនួយការលទ្ធកម្ម តាមរយៈ ទូរសព្ទលេខ ០១២ ៧១០ ៥៩៨ឬអ៊ីម៉ែល agri.taseysamaki@gmail.com ។

(៤) ដើម្បីទទួលបានឯកសារពិគ្រោះថ្លៃ អ្នកទទួលការត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- ជាក្រុមហ៊ុនសំណង់ឯកជន ឬក្រុមអ្នកម៉ៅការជីកស្រះនៅក្នុងសហគមន៍ ដែលមានអត្តសញ្ញាណសម្គាល់ ច្បាស់ លាស់ដូចជា អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(នៅមានសុពលភាព) មានបណ្ណប៉ាតង់ដែលមានសុ ពលភាព និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការសាងសង់/ចាក់ដីទៅតាមបញ្ជីប៉ាន់តម្លៃ និងលក្ខណៈ បច្ចេកទេសដែលបានកំណត់ក្នុងឯកសារពិគ្រោះថ្លៃ។ ·

- អ្នកទទួលការដែលត្រូវបានកំណត់ថាពាក់ព័ន្ធនឹងការក្លែងបន្លំ អំពើពុករលួយ និងអំពើឃុបឃិត ហើយស្ថិត ក្នុងបញ្ជីហាមឃាត់ ក្នុងអំឡុងពេលធ្វើការដេញថ្លៃ នឹងមិនមានសិទ្ធិចូលរួមដេញថ្លៃឡើយ។

(៥) សំណើពិគ្រោះថ្លៃ និងតម្លៃក្នុងសំណើពិគ្រោះថ្លៃ ត្រូវមានសុពលភាព និងជាតម្លៃថេរសម្រាប់រយៈពេល ៦០ ថ្ងៃ បន្ទាប់ពីថ្ងៃផុតកំណត់នៃការទទួលសំណើពិគ្រោះថ្លៃ។

(៦) តម្លៃសំណើពិគ្រោះថ្លៃត្រូវរួមបញ្ចូលនូវ ពន្ធអាករនានា ការដឹកជញ្ជូន ការធានារ៉ាប់រង និងចំណាយផ្សេងទៀត ។

(៧) សំណើពិគ្រោះថ្លៃមិនអនុញ្ញាតអោយមានការផ្លាស់ប្តូរឡើយ។

(៨) ការធានាលើគុណភាពសំណង់ត្រូវមានសុពលភាពយ៉ាងហោច ០៦ខែ។

(៩) សំណើពិគ្រោះថ្លៃច្បាប់ដើមត្រូវចុះហត្ថលេខាដោយអ្នកដែលបានទទួលសិទ្ធិពេញលេញដើម្បីចុះហត្ថលេខា ជំនួសមុខឱ្យអ្នកពិគ្រោះថ្លៃ។ អ្នកពិគ្រោះថ្លៃត្រូវដាក់សំណើពិគ្រោះថ្លៃក្នុងស្រោមសំបុត្រមួយបិទជិត ហើយ បញ្ជូនឱ្យបានមុន ឬត្រឹមម៉ោង**៥:០០ នាទី** រសៀល **ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៦** (មានរយៈពេលមួយសប្តា ហ៍)ទៅសហគមន៍កសិកម្មតាសីសាមគ្គី អាសយដ្ឋាន នៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង លេខទូរសព្ទ ០៨៩ ៦៦១ ០៩៩។ អ្នកទទួលការអាចទាក់ទងទៅឈ្មោះ **ចៀង សុជាត** ជាជំនួយការលទ្ធកម្ម តាមរយៈ ទូរសព្ទលេខ ០១២ ៧១០ ៥៩៨ ឬអ៊ីម៉ែល agri.taseysamaki@gmail.com។

សំណើពិគ្រោះថ្លៃដែលដាក់មកយឺតនឹងត្រូវបានបដិសេធ។ សំណើពិគ្រោះថ្លៃនឹងបើកជាសាធារណៈភ្លាមៗ បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់ឈប់ទទួលសំណើពិគ្រោះថ្លៃ នៅចំពោះមុខតំណាងអ្នកពិគ្រោះថ្លៃ ដែលអាចចូល រួមដោយផ្ទាល់។

(១០)គ្រប់សំណើពិគ្រោះថ្លៃត្រូវភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃ ដូចមានចែងក្នុងឯកសារពិគ្រោះថ្លៃ។ សំណើពិគ្រោះថ្លៃដែលមិនភ្ជាប់មកជាមួយនូវ លិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃនឹងត្រូវបដិសេធ។

(១១)សំណើពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃដោយធ្វើការកែតម្រូវការភ័ន្តច្រឡំនៃការគណនា(វេខាគណិត) ដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

(ក) នៅពេលដែលមានការខុសគ្នារវាងចំនួនទឹកប្រាក់ជាតួលេខ និងចំនួនទឹកប្រាក់ជាអក្សរ នោះចំនួនទឹកប្រាក់ជាអក្សរនឹងយកជាបានការ។

(ខ) នៅពេលដែលមានការខុសគ្នារវាងថ្លៃឯកតា និងតម្លៃសរុបនីមួយៗ ដែលបានមកពីផលគុណថ្លៃឯកតានឹងបរិមាណ នោះថ្លៃឯកតានឹងយកជាគោល។

ប្រសិនបើអ្នកពិគ្រោះថ្លៃបដិសេធមិនទទួលយកការកែតម្រូវ សំណើពិគ្រោះថ្លៃរបស់គេត្រូវបានបដិសេធ ហើយលិខិតប្រកាសស្តីពីការធានាការពិគ្រោះថ្លៃត្រូវបានអនុវត្ត។

(១២)សហគមន៍កសិកម្ម ត្រូវសម្រេចប្រគល់កិច្ចសន្យាទៅឱ្យអ្នកពិគ្រោះថ្លៃណាដែលសំណើពិគ្រោះថ្លៃរបស់គេត្រូវបានកំណត់ថាមានការឆ្លើយតបច្រើន ស្របទៅតាមបទដ្ឋាន និងលក្ខណៈបច្ចេកទេស និងបានដាក់តម្លៃពិគ្រោះថ្លៃដែលត្រូវបានវាយតម្លៃថាទាបសមស្របជាងគេ។

(១៣)ករណីពិបាកណាមួយ ក្នុងការទទួលយកឯកសារពិគ្រោះថ្លៃ អ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមពិគ្រោះថ្លៃទាំងអស់ អាចជូនដំណឹងជាលាយលក្ខអក្សរអំពីករណីពិបាកនោះដល់លោក **ណុប នុន** ជាប្រធានក្រុមប្រឹក្សាភិបាលសហគមន៍កសិកម្ម ទូរសព្ទលេខ ០៨៩ ៦៦១ ០៩៩ អាសយដ្ឋាននៅភូមិតាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង និងថតចម្លងផ្ញើជូនទៅ៖

ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបន្ថែម នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា ដែលមានអាសយដ្ឋាននៅជាន់ផ្ទាល់ដីនៃនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាយសដ្ឋាន៖# ២០០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

(១៤) បន្ទាប់ពីការសម្រេចប្រគល់កិច្ចសន្យាត្រូវបានប្រកាស អ្នកពិគ្រោះថ្លៃដែលបរាជ័យមានសិទ្ធិស្នើសុំឱ្យមានការពន្យល់ ដើម្បីដឹងច្បាស់ពីមូលហេតុនៃការបរាជ័យនៃសំណើពិគ្រោះថ្លៃរបស់ខ្លួន ហើយគណៈកម្មការលទ្ធកម្មរបស់សហគមន៍កសិកម្ម មានកាតព្វកិច្ចផ្តល់ការពន្យល់នេះ។ ការសម្ងាត់ផ្ទាល់ខ្លួនរបស់អ្នកពិគ្រោះថ្លៃត្រូវបានរក្សាជាការសម្ងាត់ មិនឱ្យភាគីផ្សេងទៀតបានដឹងឡើយ។

(១៥) បណ្តឹងតវ៉ាត្រូវបញ្ជូនទៅប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម ។ ប្រធានក្រុមប្រឹក្សាភិបាលនឹងធ្វើការអង្កេតលើមូលដ្ឋាននៃកាតវ៉ា និងធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល៧ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានបណ្តឹងតវ៉ានេះ លើកលែងតែក្នុងករណីការតវ៉ា ដែលបានទទួលក្នុងអំឡុងពេលវាយតម្លៃ។ ការតវ៉ាដែលទទួលបានក្នុងអំឡុងពេលវាយតម្លៃសំណើពិគ្រោះ ត្រូវបានពិនិត្យមើលដោយគណកម្មការលទ្ធកម្មនៃសហគមន៍កសិកម្ម ហើយការឆ្លើយតប នឹងធ្វើឡើងបន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់ប៉ុណ្ណោះ។

ក្នុងករណីការឆ្លើយតបរបស់ប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្ម មិនបំពេញតាមបំណងរបស់អ្នកពិគ្រោះថ្លៃចាញ់ ឬពុំមានការឆ្លើយតបណាមួយត្រូវបានធ្វើឡើងនោះទេ នោះអ្នកតវ៉ាត្រូវដាក់បណ្តឹងតវ៉ា ទៅកាន់ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបំពេញបន្ថែម។ ក្រុមរដ្ឋបាលគ្រប់គ្រងទុនវិនិយោគបំពេញបន្ថែមត្រូវឆ្លើយតបការតវ៉ាក្នុងរយៈពេល ៧ ថ្ងៃប្រតិទិន។ ករណីនេះមិនបណ្តាលឱ្យមានការបាត់បង់សិទ្ធិរបស់អ្នកពិគ្រោះថ្លៃ ចំពោះការប្តឹងបន្តណាមួយផ្សេងទៀតដែលអ្នកពិគ្រោះថ្លៃអាចជ្រើសរើសនោះទេ។

(១៦) គោលការណ៍របស់សមាគមអភិវឌ្ឍន៍អន្តរជាតិតម្រូវឱ្យអ្នកខ្ចី (រួមទាំងអ្នកទទួលផលពីប្រាក់កម្ចីពីធនាគារ) អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ អ្នកទទួលការ និងភ្នាក់ងាររបស់ពួកគេ (ទោះជាប្រកាស ឬមិនប្រកាស) អ្នកទទួលការបន្ត អ្នកប្រឹក្សាបន្ទាប់ អ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់ និងបុគ្គលិកណាមួយ គោរពតាមស្តង់ដារខ្ពស់បំផុតនៃក្រមសីលធម៌វិជ្ជាជីវៈ ក្នុងអំឡុងពេលកិច្ចលទ្ធកម្មនិងក្នុងការអនុវត្តកិច្ចសន្យាដែលផ្តល់ហិរញ្ញប្បទានដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ។

(១៧) អ្នកទទួលការ អ្នកផ្គត់ផ្គង់ និងអ្នកផ្តល់សេវាទាំងអស់ត្រូវអនុញ្ញាតឱ្យសមាគមអភិវឌ្ឍន៍អន្តរជាតិ និង/ឬអ្នកដែលត្រូវបានតែងតាំងដោយសមាគមអភិវឌ្ឍន៍អន្តរជាតិត្រួតពិនិត្យ ការដ្ឋាន គណនី និងឯកសារទាំងអស់ដែលទាក់ទងនឹងការអនុវត្តកិច្ចសន្យា និងការដាក់សំណើពិគ្រោះថ្លៃ ហើយគណនី និងកំណត់ត្រាទាំងនេះត្រូវបានធ្វើសវនកម្មដោយសវនករដែលត្រូវបានតែងតាំងដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ ប្រសិនបើត្រូវបានស្នើសុំដោយសមាគមអភិវឌ្ឍន៍អន្តរជាតិ ។

ធ្វើនៅតាសី ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៥

**ប្រធានក្រុមប្រឹក្សាភិបាលនៃសហគមន៍កសិកម្មតាសីសាមគ្គី**

**ហត្ថលេខា**

សហគមន៍កសិកម្មតាសីសាមគ្គី
Tasey Samaki Agricultural Cooperative

**ឈាប នុន**